ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីជូនព័ត៌មាន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដូចខាងក្រោម ដែលមានមូលបទ «រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ រួមចំណែកជាមួយពិភពលោក» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១២ ដល់ ថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន តបតាមការអញ្ជើញរបស់ឯកឧត្តម **រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ** (Rodrigo Roa Duterte) ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន៖

- កិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១
- កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សហរដ្ឋអាមេរិកលើកទី ៤០
- កិច្ចប្រជុំកំពូលអាស៊ាន - ចិនលើកទី ២០
- កិច្ចប្រជុំកំពូលអាស៊ាន - សាធារណរដ្ឋកូរ៉េលើកទី ១៩
- កិច្ចប្រជុំកំពូលអាស៊ាន - ជប៉ុនលើកទី ២០
- កិច្ចប្រជុំកំពូលអាស៊ាន - អង្គការសហប្រជាជាតិលើកទី ៩
- កិច្ចប្រជុំកំពូលអាស៊ានបូក ៣ លើកទី ២០
- កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-កាណាដាលើកទី ៤០
- កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុបលើកទី ៤០
- កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ១២
- កិច្ចប្រជុំកំពូលអាស៊ាន - ឥណ្ឌាលើកទី ១៥

គណៈប្រតិភូអមដំណើររួមមាន ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **ប៉ាន់ សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងសមាជិករដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាដទៃទៀត។

ក្រៅពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងអញ្ជើញចូលរួមកិច្ចប្រជុំ និងសកម្មភាពនានា ដូចខាងក្រោម៖

- កិច្ចប្រជុំរវាងនាយករដ្ឋមន្ត្រីទាំងបី នៃ ប្រទេស កម្ពុជា ឡាវ និងវៀតណាម
- ជំនួបរវាងថ្នាក់ដឹកនាំអាស៊ានបូកបី ជាមួយនឹងក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ីបូព៌ា
- កិច្ចប្រជុំកំពូលមេគង្គ - ជប៉ុនលើកទី៩

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

- កិច្ចប្រជុំថ្នាក់ដឹកនាំនៃ«ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់» (RCEP)
- ពិធីលៀងសាយភោជន៍ពិសេស ដើម្បីអបអរសាទរខួប៥០ ឆ្នាំ នៃការបង្កើតអាស៊ាន
- ពិសារអាហារថ្ងៃត្រង់ រៀបចំដោយប្រធានាធិបតី រ៉ូឌ្រីហ្គោឌូតឺតេ ជាកិត្តិយសដល់ប្រមុខរដ្ឋ/រដ្ឋាភិបាល និងភ្ញៀវរបស់ប្រធានកិច្ចប្រជុំ។

បន្ថែមពីនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក៏នឹងជួបពិភាក្សាទ្វេភាគីផងដែរជាមួយ ឯកឧត្តម លី ខឺឈាង (Li Keqiang) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម ម៉ាលខុម ថើន បុល (Malcolm Turnbull) នាយករដ្ឋមន្ត្រីនៃប្រទេសអូស្ត្រាលី ឯកឧត្តម ណារិនដ្រា មូឌី (Narendra Modi) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា ឯកឧត្តមឌីមីទ្រី ម៉េដវ៉េដេវ (Dmitry Medvedev) នាយករដ្ឋមន្ត្រីនៃសហព័ន្ធរុស្ស៊ី ឯកឧត្តមអាន់តូញ៉ូ ហ្គុយតេរេស (Antonio Guterres) អគ្គលេខាធិការអង្គការសហប្រជាជាតិ និងថ្នាក់ដឹកនាំគណៈប្រតិភូនៃប្រទេសមួយចំនួនទៀត។

នៅមុនពេលកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ សម្តេចតេជោ នឹងអញ្ជើញបំពេញទស្សនកិច្ច នៅទីក្រុងក្លាក ខេត្តប៉ាំប៉ាងហ្គា ប្រទេសហ្វីលីពីន នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៧ តបតាមការអញ្ជើញរបស់លោកជំទាវ **គ្លោរីយ៉ា ម៉ាកាប៉ាហ្គាល អារ៉ូយ៉ូ (Gloria Macapagal-Arroyo)** អតីតប្រធានាធិបតីហ្វីលីពីន និងជាសមាជិកសភាមណ្ឌល ប៉ាំប៉ាងហ្គាទី២។

ក្នុងឱកាសទស្សនកិច្ចនេះ សម្តេចតេជោ នឹងអញ្ជើញទៅទស្សនាតំបន់កំពង់ផែរួចពន្ធ ក្លាក ដើម្បីពិនិត្យមើលរបៀបគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធរបស់តំបន់នេះ ដែលនឹងផ្តល់ជាប្រយោជន៍ សម្រាប់ការអភិវឌ្ឍនៅកម្ពុជា។ សម្តេចតេជោ ក៏នឹងអញ្ជើញពិសារអាហារពេលល្ងាច រៀបចំដោយលោកជំទាវ គ្លោរីយ៉ា ម៉ាកាប៉ាហ្គាល អារ៉ូយ៉ូ ផងដែរ។/

ភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០១៧